ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពី

## លទ្ធផលការងាររបស់ព្រឹទ្ធសភា

## ប្រចាំខែមករា ឆ្នាំ២០១៩

នៅក្នុងខែមករា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖**

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០៣លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អនុញ្ញាតឱ្យឯកឧត្តម Nguyen ThiKimNgan ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឱ្យឯកឧត្តម Seott Ryan ប្រធានព្រឹទ្ធសភា នៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសម

-អនុញ្ញាតជូនឯកឧត្តម Wang Wentian ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឱ្យឯកឧត្តម TRAN CAMTU លេខាធិការមជ្ឈិមបក្ស និងជាប្រធានគណៈកម្មាធិការត្រួតពិនិត្យមជ្ឈិមបក្សកុំម្មុយនីស្តវៀតណាម និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឱ្យឯកឧត្តម Andrei Klimov ប្រធានគណៈកម្មការនៃអគ្គក្រុមប្រឹក្សាភិបាលគណបក្ស United Russia ទទួលបន្ទុកកិច្ចការអន្តរជាតិ និងជាអនុប្រធានគណៈកម្មាធិការអន្តរជាតិ នៃក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសម

-អនុញ្ញាតឱ្យឯកឧត្តម ILYAS UMAKANOV អនុប្រធានក្រុមប្រឹក្សាសហព័ន្ធរុស្ស៊ី និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម

-អញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបុណ្យឆ្លងចូលឆ្នាំថ្មីឆ្នាំសកលឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយក-រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឈ្នះ ឈ្នះ

-អញ្ជើញចូលរួមជាកិត្តិយស និងថ្លែងសុន្ទរកថាក្នុងកម្មវិធីបើកកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិចលើកទី២៧(APPF-27) ក្រោមមូលបទ ការពង្រឹងភាពជាដៃគូសភា ដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍ ប្រកបដោយចីរភាព

-អញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីប្រារព្ធមហាមិទ្ទិញខួបលើកទី៤០នៃទិវាជ័យជម្នះ៧មករា នៅពហុកីឡដ្ឋានជាតិអូឡាំពិក

-អញ្ជើញចូលរួមពិធីប្រកាសជាផ្លូវការនៃក្រុមប្រឹក្សាវប្បធម៌អាស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន់** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានស្ថាបនិកកិត្តិយសនៃក្រុមវប្បធម៌អាស៊ី

-អញ្ជើញចូលរួមប្រកួតកីឡាវាយកូនគោលពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីក្នុងព្រឹត្តិការណ៍សម្ពោធវិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ របស់**សម្តេចតេជោ ហ៊ុន សែន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីលានវាយកូនគោលហ្គាឌិនស៊ីធី

-អញ្ជើញជាអធិបតីក្នុងពិធីប្រកួតកីឡាវាយកូនគោលផ្នែកនារីពានរង្វាន់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ឆ្នាំ២០១៩ ទីលានវាយកូនគោល

-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមកីឡាបាល់ទាត់ និងសាកសួរសុខទុក្ខលោកគ្រូ អ្នកគ្រូសាលាបឋមសិក្សាវត្តទួលទំពូង

-អញ្ជើញរៀបចំប្រារព្ធពិធីបុណ្យគម្រប់០១ឆ្នាំ ដើម្បីឧទ្ទិសកុសលជូនដួងវិញ្ញាណ-ក្ខន្ធឧបាសក **គង់ ខាត់** បិតាក្មេករបស់សម្តេច នៅវត្តសុវណ្ណគិរីជើងឆ្នុក ភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-អញ្ជើញជាអធិបតីប្រទានភ្លើងបូជាសពឯកឧត្តម **ផន សូគីម** អគ្គលេខាធិការរងព្រឹទ្ធសភា នៅទីមេរុក្នុងបរិវេណវត្តសុវណ្ណមុន្នីសាគរ (វត្តសំរោងអណ្តែត) សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២២ច្បាប់ ។

**១.២.ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញចូលរួមប្រជុំពិភាក្សាការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-អញ្ជើញចូលរួមពិធីសម្ពោធវិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ និងពិធីបុណ្យចូលឆ្នាំសកល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមពិធីអបអរសាទរថ្ងៃជ័យជម្នះ៧មករា លើកទី៤០ឆ្នាំ (៧មករា ១៩៧៩- ៧ មករា ២០១៩) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិអូឡាំពិក

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤២ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន ០២លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញចូលរួមពិធីខួបអនុស្សាវរីយ៍លើកទី៤០ នៃទិវាជ័យជម្នះសង្គ្រាមការពារព្រំដែននិរតីវៀតណាម និងការតស៊ូជាមួយកងទ័ព និងប្រជាពលរដ្ឋកម្ពុជា ដណ្តើមបានជ័យជម្នះលើរបបប្រល័យពូជសាសន៍ **ប៉ុល ពត** ព្រមទាំងបានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោកជំទាវ **ង្វៀន ធិគីមង៉ិន** ប្រធានរដ្ឋសភាវៀតណាម និងឯកឧត្តមប្រធានគណៈកម្មាធិការមជ្ឈិមរណសិរ្សមាតុភូមិវៀតណាម នៅទីក្រុងហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-អញ្ជើញចូលរួមក្នុងពិធីរៀបចំក្រុងពាលី និងចូលរួមជាកិត្តិយសក្នុងពិធីប្រារព្ធខួបលើកទី៤០ នៃទិវាជ័យជម្នះ៧មករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅពហុកីឡដ្ឋានអូឡាំពិក

-អញ្ជើញចូលរួមពិធីសម្ពោធវិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមក្នុងពិធីអបអរសាទររំលឹកខួបលើកទី២០ ថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើកវេទិកាថ្នាក់ខេត្តស្តីពី ការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន នៅខេត្តកំពង់ធំ

-អញ្ជើញចូលរួមប្រជុំបូកសរុបសកម្មភាពការងារសមាគមមិត្តភាពកម្ពុជា-ចិន ឆ្នាំ២០១៨ ទិសដៅឆ្នាំ២០១៩ និងជប់លៀងស្វាគមន៍ឯកអគ្គរដ្ឋទូតចិនថ្មីប្រចាំកម្ពុជា នៅតំបន់អភិវឌ្ឍន៍បឹងកក់

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅសង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៣លើក:**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានប្រជុំចំនួន០៣លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

៣.ពិនិត្យ និងសម្រេចលើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០១៨

៤.ពិនិត្យ និងសម្រេចអំពីគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០១៩ ។

**៣.សម័យប្រជុំពេញអង្គចំនួន០១លើក** :

ព្រឹទ្ធសភាប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើ៖

១.សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២.សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមករានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៤.១.មុខងារនីតិកម្ម**

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការ ព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងរាស្ត្រហត្ថលេខី ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីស្នើច្បាប់ចំនួន០២ច្បាប់ ។

**៤.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០២ករណី ផ្ញើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ០២ករណី និងទទួលឯកសារពាក្យបណ្តឹងពីក្រសួងស្ថាប័នដែលចម្លងជូនមកព្រឹទ្ធសភាជ្រាបចំនួន៤០ករណី

-អញ្ជើញចូលរួមវេទិកាថ្នាក់ខេត្ត ក្រោមប្រធានបទស្តីពី ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន

-គណៈកម្មការរៀបចំកសាងផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំ បានបើកកិច្ចប្រជុំត្រួតពិនិត្យ និងពិភាក្សាលើគម្រោងបែងចែកកញ្ចប់ថវិកាឆ្នាំ ២០១៩

-អញ្ជើញចូលរួមវេទិកាអាស៊ី-ប៉ាស៊ីហ្វិច (APPF) លើកទី២៧ ក្រោមមូលបទ ការពង្រឹងភាពជាដៃគូសភា ដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍ ប្រកបដោយចីរភាព

-អញ្ជើញប្រជុំពិភាក្សាការងារដើម្បីត្រៀមរៀបចំសិក្ខាសាលាស្តីពី ការចែករំលែកព័ត៌មានអំពីការអនុវត្តការិយាល័យថវិកាសភានៅប្រទេសស៊ុយអែត និងប្រទេសកាណាដា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៨៣លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិ-

មនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និង គោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន១០២លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **ជា ជេដ្ឋ** ឯកឧត្តម **សាយ បូរិន** និងលោកជំទាវ **ស៊ី វណ្ណថា** អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល (PFWB) នៃប្រទេសប៊ែលហ្ស៊ិក

-ឯកឧត្តម **ម៉ុង ឫទ្ធី** អញ្ជើញទទួលស្វាគមន៍លោក KIM HEANG ប្រធានក្រុមហ៊ុនអចលនទ្រព្យKW ព្រមទាំងដឹកនាំក្រុមអ្នកជំនាញបច្ចេកទេសចំនួន៥១នាក់ ដើម្បីសិក្សាស្វែងយល់អំពីវិស័យអចលនទ្រព្យ និងសាងសង់លំនៅដ្ឋានលំហែកាយនៅតំបន់កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ